ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១០០/១១-ណាក់ហ្គេត**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **តាំង ទ្រី**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ (ភីធីអី) អិលធីឌី**

អាសយដ្ឋាន : ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៦៨៩ ៨៩៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោកស្រី ឌុក សុជាតា ប្រធានរដ្ឋបាល

២- កញ្ញា ឌុក ច័ន្ទពិសី ជំនួយការរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា**

**- សហជីពសេដ្ឋកិច្ចកម្មករកម្ពុជា រោងចក្រ ណាក់ហ្គេត តេចស្តាយ**

អាសយដ្ឋាន : អាគារ E ផ្លូវលេខ ២១ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៦៣៦ ៧៦៦ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក អឿ ទី | ប្រធានសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា |
| ២- លោក ស្រៀង ណារិទ្ធ | អនុប្រធានសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា |
| ៣- កញ្ញា ខឹម ស្រីម៉ាច | ប្រធានសហជីពសេដ្ឋកិច្ចកម្មករកម្ពុជារោងចក្រ ណាក់ហ្គេត |
| ៤- លោក កើត សោភ័ណ្ឌ | អនុប្រធានសហជីពសេដ្ឋកិច្ចកម្មករកម្ពុជារោងចក្រ ណាក់ហ្គេត |
| ៥- កញ្ញា ខេន ញឹម | លេខាធិការសហជីព |
| ៦- កញ្ញា ប៊ុត ផល្លី | តំណាងកម្មករ |
| ៧- កញ្ញា ផាន តួយ | តំណាងកម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់លុយថ្លៃផ្លូវដល់កម្មករទាំងអស់ ទាំងកម្មករចាស់ ទាំងកម្មករថ្មី។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់លុយថ្លៃផ្លូវដល់កម្មករនិយោជិតថ្មីបានឡើយ (គិតចាប់ពីផ្លូវដែលល្អ)។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរៀបចំឱ្យមានទារកដ្ឋានក្នុងក្រុមហ៊ុន។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចសាងសង់ទារកដ្ឋានបានឡើយ ដោយហេតុថាក្រុមហ៊ុនបានផ្តល់លុយចំនួនប្រាំបីដុល្លារអាមេរិក ដល់កម្មការនីរួចហើយ។

៣- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនឱ្យស្ត្រីមានផ្ទៃពោះចាប់ពី ២ ខែ ឡើងទៅ ត្រូវឱ្យចេញមុន ១៥ នាទី។ ដោយឡែកភាគីក្រុមហ៊ុនរក្សាដដែល ៥ នាទី ចេញមុន ចំពោះកម្មការិនីដែលអាចមើលឃើញពោះធំដោយភ្នែក។

៤- កម្មករនិយោជិតទាមទារកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងរក្សាប្រាក់រង្វាន់ផ្សេងៗនៅដដែលចំពោះកម្មការិនីដែលចូលរួមធ្វើកូដកម្ម នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ជូនកម្មករនិយោជិតដែលចូលរួមធ្វើកូដកម្ម។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៨៨៦ ក.ប/អក/វ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរស័ព្ទរបស់សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា ស្តីពីការដែលកម្មករនិយោជិតនៃក្រុមហ៊ុន ណាក់ហ្គេតតេចស្តាយ (ភីធីអ៊ី) អិលធីឌី ធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរជូនកម្មករនិយោជិត។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះដល់ទីតាំងក្រុមហ៊ុន ធ្វើការដោះស្រាយវិវាទការងាររួមនេះ និងផ្សះផ្សា នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១០ ចំណុច លើការទាមទារចំនួន ១៤ ចំណុច ។ ចំណុចមិនសះជាចំនួន ០៤ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨៨៦ កប/អក/វ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ ភាគីទាំងពីរបានជូនដំណឹងថា ចំណុចវិវាទនៅសេសសល់ក្នុងសំណុំរឿងនេះ មានតែ ០៣ ចំណុច ប៉ុណ្ណោះ ព្រោះពួកគាត់មានកិច្ចព្រមព្រៀងបន្ថែមទៀត ក្រោយពីការផ្សះផ្សានៅនាយកដ្ឋានវិវាទការងារ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ បន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចទី២ និងទី៣ ចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី១ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទទី១ ដែលនៅសល់ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**តស្វនាខ**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ ភីធីអ៊ី អិលធីឌី ផ្ទេរសិទ្ធិជូន លោកស្រី ឌុក សុជាតា ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១។

២- កិច្ចព្រមព្រៀងរវាងភាគីនិយោជក ណាក់ហ្គេត តេចស្តាយ និងសហជីពកម្មករនិយោជិត ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេដ្ឋកិច្ចកម្មករកម្ពុជារោងចក្រ ណាក់ហ្គេត តេចស្តាយ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ។

២- លិខិតរបស់សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា លេខ ០១៥៤/១១ ស.ស.ស.ក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១១ គោរពជូន លោកនយកក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ ស្តីពីកាជូនដំណឹងអំពីសមាសភាពជាប់ឆ្នោតថ្នាក់ដឹកនាំថ្មី នៃសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា រោងចក្រ ណាក់ហ្គេត តេចស្តាយ។

៣- លិខិតជូនដំណឹងធ្វើកូដកម្ម រឺបាតុកម្មអហឹង្សា របស់កម្មករ-កម្មការនី នៃរោងចក្រ ណាក់ហ្គេត តេចស្តាយ ជម្រាបជូន លោកនាយកក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ ស្តីពីជូនដមណឹងចំនួន ៧ ថ្ងៃ ធ្វើកូដកម្ម រឺបាតុកម្មអហឹង្សា នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១។

៤- លិខិតជូនដំណឹងធ្វើកូដកម្ម រឺបាតុកម្មអហឹង្សា របស់សហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីជូនដមណឹងចំនួន ៧ ថ្ងៃ ធ្វើកូដកម្ម រឺបាតុកម្មអហឹង្សា នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ លេខ ០១៧/១១ ស.ស.ស.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១។

៥- ស្នាមមេដៃរបស់កម្មករ-កម្មការិនីរោងចក្រ ណាក់ហ្គេត តេចស្តាយ ស្នើសុំឱ្យសហព័ន្ធសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា ជួយដោះស្រាយនៅបណ្តឹង និងសំណូមពរមួយចំនួន។

៦- ស្នាមមេដៃកម្មករ-កម្មការិនី រោងចក្រ ណាក់ហ្គេត ស្នើសុំឱ្យក្រុមហ៊ុនដករដ្ឋបាលឈ្មោះ ឌុក សុជាតា និងអ្នកបកប្រែ ឈ្មោះ ម៉េង ចេញពីរោងចក្រ ០៥ ខែសីហា ឆ្នាំ២០១១។

៧- កិច្ចព្រមព្រៀងរវាងភាគីក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ និងបងប្អូនកម្មករនិយោជិត នៃក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាក់ហ្គេត តេចស្ពាយ លេខ ៨៨៦ ក.ប/អក/វ.ក ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ណាក់ហ្គេត តេចស្ពាយ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៩៧២ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៩៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ណាក់ហ្គេត តេចស្ពាយ មានជួលកម្មករនិយោជិតសរុបចំនួន ៤៨០ នាក់។
- នៅក្នុងក្រុមហ៊ុនមានសហជីពបី គឺសហជីពសម្លេងយុវជនខ្មែរ សហជីពយុវជនខ្មែរ និងសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា។ សហជីពសេដ្ឋកិច្ចកម្មករកម្ពុជា ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ មានសមាជិកចំនួន ២០០ នាក់។ នៅក្នុងក្រុមហ៊ុន មិនមានសហជីពណាមានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់លុយថ្លៃផ្លូវដល់កម្មករទាំងអស់ ទាំងកម្មករចាស់ ទាំងកម្មករថ្មី**

- ចាប់ពីខែធ្នូ ឆ្នាំ២០០៧ នៅពេលដែលផ្លូវធ្វើដំណើរចូលទៅកាន់ក្រុមហ៊ុនមានដីភក់ ដើរជាន់កប់ជើង ពិបាកធ្វើដំណើរមកទៅធ្វើការ។ និយោជកក៏បានឧបត្ថម្ភដល់កម្មករនិយោជិត ជាទឹកប្រាក់ចំនួន ៥ ដុល្លារអាមេរិក សម្រាប់មួយខែ ហើយក្រោយពេលដែលផ្លូវនោះត្រូវបានជួសជុលស្អាតឡើងវិញ

ហើយនិយោជក ក៏បានប្រកាសថា និយោជកនឹងឈប់ផ្តល់ប្រាក់ឧបត្ថមនេះ ជូនកម្មករចូលថ្មីទៀតហើយ ។

- រហូតដល់ខែធ្នូ ឆ្នាំ២០០៩ ផ្លូវត្រូវបានជួសជុលស្អាត។ ដោយនិយោជកយល់ឃើញថា គាត់ធ្លាប់បានផ្តល់ប្រាក់នេះ ដល់កម្មករនិយោជិតតាំងពីឆ្នាំ២០០៧ កន្លងមក ហេតុនេះ គាត់មិនបានដកវិញទេ ។ ជាលទ្ធផល និយោជកនៅតែបន្តផ្តល់ប្រាក់ ៥ ដុល្លារអាមេរិក សម្រាប់មួយខែនេះ ដល់កម្មករនិយោជិត ដោយកំណត់ក្នុងតារាងបើកប្រាក់ខែរបស់កម្មករនិយោជិតថា "ជាប្រាក់ឧបត្ថម្ភ" ។
- ចាប់ពីខែមករា ឆ្នាំ២០១០ មានកម្មករនិយោជិតថ្មីៗចូលធ្វើការ និងធ្វើការទាមទារប្រាក់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារ អាមេរិក សម្រាប់មួយខែ ដូចដែលកម្មករនិយោជិតមួយចំនួនរបស់ក្រុមហ៊ុនធ្លាប់ និងកំពុងទទួលតាំងពីពេលផ្លូវមិនទាន់ត្រូវបានជួសជុលរហូតដល់បានជួសជុលស្អាត ។
- កម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតដែលចូលធ្វើការមុន និងចាប់ពីឆ្នាំ២០១០ ជាកម្មករនិយោជិតរបស់ក្រុមហ៊ុនដូចគ្នាទេ ហេតុនេះក្រុមហ៊ុនមិនត្រូវមានការរើសអើងក្នុងការផ្តល់អត្ថប្រយោជន៍នេះទេ ។
- នៅពេលនិយោជករើសកម្មករនិយោជិតឱ្យចូលធ្វើការ និយោជកតែងប្រកាសផ្សាយពីអត្ថប្រយោជន៍ដែលកម្មករនិយោជិតនឹងទទួលបាន ប្រសិនបើនិយោជករើសចូលធ្វើការ។ នៅក្នុងការរើសកម្មករនិយោជិតពីឆ្នាំ២០១០ និយោជកបានប្រកាសថា គាត់នឹងមិនទទួលបានប្រាក់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក សម្រាប់មួយខែនោះទេ។ កម្មករនិយោជិតចូលថ្មី ត្រូវបានដឹងច្បាស់ពីអ្វីដែលគាត់នឹងទទួល ឬនឹងមិនទទួលបាន នាពេលរើសឱ្យចូលធ្វើការ ។

## ហេតុផលនៃសេចក្តីសម្រេច

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារអាមេរិក សម្រាប់មួយខែ ជូនដល់កម្មករនិយោជិតថ្មីដែលទើបបានចូលធ្វើការចាប់ពីឆ្នាំ២០១០ ក្រោយពេលដែលផ្លូវត្រូវបានជួសជុលស្អាត ដែរ ឬទេ?

តាមអង្គហេតុ ភាគីនិយោជកធ្លាប់បានផ្តល់ប្រាក់ ៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតតាំងពីខែធ្នូ ឆ្នាំ២០០៧ ដោយមូលហេតុនៅពេលនោះផ្លូវមានដីភក់ ពិបាកធ្វើដំណើរទៅកាន់ក្រុមហ៊ុន ។ នៅពេលផ្លូវស្អាតក៏ដោយ ក៏និយោជកនៅតែបន្តឱ្យ ព្រោះគាត់មិនដកហូតនូវអ្វីដែលគាត់បានធ្លាប់ផ្តល់ជូនកម្មករចាស់កន្លង

មកនោះទេ។ លើសពីនេះ ប្រាក់ដែលគាត់ផ្តល់ឱ្យនោះ មានន័យជាប្រាក់ឧបត្ថម្ភ (មិនមែនប្រាក់ថ្លៃធ្វើដំណើរ) ដូចមានបង្ហាញក្នុងតារាងបើកប្រាក់របស់កម្មករនិយោជិតប្រចាំខែ។

ជាងនេះទៅទៀត នៅពេលនិយោជករើសកម្មករនិយោជិតឱ្យចូលធ្វើការក្នុងឆ្នាំ២០១០ ម្តងៗ និយោជកបានប្រកាសប្រាប់ពីដំបូងនូវអត្ថប្រយោជន៍ដែលកម្មករនិយោជិតនឹងទទួល ឬ នឹងមិនទទួលបាន ជាដោយឡែកកម្មករនិយោជិតនឹងមិនទទួលបានប្រាក់ ៥ ដុល្លារ អាមេរិក សម្រាប់មួយខែ ជាថ្លៃធ្វើដំណើរនោះទេ ។

លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ឃើញថា មិនមានមាត្រានៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ឬបទប្បញ្ញត្តិណាមួយ ដែលតម្រូវឱ្យនិយោជកត្រូវផ្តល់ប្រាក់ចំនួន ៥ ដុល្លារអាមេរិក ក្នុងមួយខែ ជូនដល់កម្មករនិយោជិតដែលទើបតែរើសចូលធ្វើការចាប់ពីឆ្នាំ២០១០ នោះទេ។ ការទាមទាររបស់កម្មករនិយោជិតសម្រាប់ចំណុចវិវាទនេះ ជាការទាមទារលើសពីការកំណត់ក្នុងច្បាប់។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺជាវិវាទអំពីផលប្រយោជន៍។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីវិវាទ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនឹងផ្តល់គុណវុឌ្ឍិផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការលើកសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ម្យ៉ាងវិញទៀត ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលដោះស្រាយវិវាទអំពីប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះ ចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីជំនួសសេចក្តីបង្គាប់នេះ"*។

ផ្អែកលើប្រការ ៤៣ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា បើក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់ដែលដោះស្រាយវិវាទអំពីប្រយោជន៍ វានឹងក្លាយជាអនុសញ្ញារួមរយៈពេលមួយឆ្នាំ។ ជាទូទៅ អនុសញ្ញារួមត្រូវបានអនុវត្តចំពោះកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ហើយសិទ្ធិក្នុងការធ្វើកូដកម្មមិនអាចអនុវត្តឡើងសម្រាប់សើរើឡើងវិញនូវអនុសញ្ញារួម នៅពេលដែលអនុសញ្ញារួមនោះមិនទាន់ផុតកំណត់នោះទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៩២/០៨-វិលសិន ហេតុផលចំណុចវិវាទទី២)*។

ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៧/០៦-ដាយយ៉ាំង ហេតុផលនៃចំណុចវិវាទទី៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ថា *"សិទ្ធិនេះ ជារបស់សហជីពដែលបានចុះបញ្ជិកា ដែលមានសមាជិកច្រើនជាងគេ ហើយបំពេញបានតាមលក្ខណៈវិនិច្ឆ័យឯទៀត ដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ"*។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាការទាមទារទាក់ទងនឹងវិវាទប្រយោជន៍នេះ កាលណាសហជីពដែលនាំយកវិវាទនោះមក ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧១/០៩-ហាយតិច ហេតុផលចំណុចវិវាទទី១០, លេខ ៨៤/១០-មីងដាហ្វូតវៀ ហេតុផលចំណុចវិវាទទី៣)* ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ គឺក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារមកនោះ ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ ។

នៅក្នុងសំណុំរឿងនេះ សហជីពសេដ្ឋកិច្ចកម្មករកម្ពុជា រោងចក្រ ណាក់ហ្គេត តេចស្តាយ មិនមានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីពសេដ្ឋកិច្ចកម្មករកម្ពុជានេះ មិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានសិទ្ធិតាមច្បាប់ ក្នុងការលើកយកវិវាទដែលទាក់ទងទៅនឹងផលប្រយោជន៍រួមរបស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ណាក់ហ្គេត តេចស្តាយ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយនៅឡើយទេ។ មានតែសហជីពដែលមានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិតំណាងផលប្រយោជន៍រួម ឱ្យកម្មករនិយោជិតទាំងអស់ក្នុងការទាមទារនូវអ្វីដែលលើសពីច្បាប់បានចែង ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារ អាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែលចូលធ្វើការចាប់ពីឆ្នាំ២០១០។

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១:** បដិសេធពិចារណាការទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃធ្វើដំណើរចំនួន ៥ ដុល្លារ អាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែលចូលធ្វើការចាប់ពីឆ្នាំ២០១០។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។-៕*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុត វី**

ហត្ថលេខា: ----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **តាំង ទ្រី**

ហត្ថលេខា: ----------------------------------